


## ខចែង និងលក្ខខណ្ឌ

### ១. រយៈពេលនៃប្រូម៉ូសិន

KHQR Merchant ប្រូម៉ូសិន ត្រូវបានរៀបចំឡើងដោយ សាជីវកម្មធនាគារកាថេយ្យូណៃធីត(កម្ពុជា)ចំកាត់ (“CUBC”) ។ ប្រូម៉ូសិននេះនឹងមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០២៤។

### ២. រង្វាន់

អតិថិជននឹងមានសិទ្ធិឈ្នះរង្វាន់ និងការផ្តល់ជូនពិសេសខាងក្រោម បន្ទាប់ពីបំពេញលក្ខខណ្ឌក្នុងប្រូម៉ូសិននេះ។

I. ទទួលបានការប្រាក់បន្ថែម P.A. ១.៥ភាគរយ លើអត្រាការប្រាក់បច្ចុប្បន្ន (ការប្រាក់ខ្ពស់បំផុតគិតជាទឹកប្រាក់រហូតដល់ ១៥ ដុល្លារក្នុងមួយខែ) និង
II. ទទួលបានឱកាសចូលរួមចាប់រង្វាន់ជាសាច់ប្រាក់រហូតដល់ ២៥០ ដុល្លារ ដែលនឹងធ្វើឡើងជារៀងរាល់ខែ និង រង្វាន់ជាសាច់ប្រាក់ ៥០០ ដុល្លារមួយលើក ដែលនឹងធ្វើឡើងក្រោយការបញ្ចប់នៃប្រូម៉ូសិននេះ។

### ៣. លក្ខណៈសម្បត្តិ និងសិទ្ធិមុនពេលចូលរួម

- ប្រូម៉ូសិននេះផ្តល់ជូនសម្រាប់ អតិថិជនរបស់សាជីវកម្មធនាគារកាថេយ្យូណៃធីត (កម្ពុជា) ចំកាត់ ដែលមានគណនីប្រាក់សន្សំ និងគណនីឌីជីថល ព្រមទាំងបានស្នើសុំ KHQR ពី CUBC
- ប្រូម៉ូសិននេះផ្តល់ជូនសម្រាប់ អតិថិជនដែលមានសមតុល្យប្រចាំខែចាប់ពី ៥០០.០០ ដុល្លារ  រហូតដល់ ១០,០០០.០០ ដុល្លារឬសមមូលនឹងប្រាក់រៀល។

**៤. លក្ខខណ្ឌក្នុងការឈ្នះរង្វាន់**

I. **សម្រាប់រង្វាន់ជាសាច់ប្រាក់ចំនួន ១០០ ដុល្លារៈ**
- អតិថិជនរបស់សាជីវកម្មធនាគារកាថេយ្យូណៃធីត(កម្ពុជា)ចំកាត់ ទាំងអស់ត្រូវមានប្រតិបត្តិការទទួលប្រាក់ពីធនាគារដទៃ តាមរយ: KHQR ចាប់ពី ១០ដង ឡើងទៅ
- អតិថិជនត្រូវមានសមតុល្យជាមធ្យមប្រចាំខែពី ៥០០.០០ដុល្លារ រហូតដល់ ១, ០០០.០០ ដុល្លារ ឬសមមូលនឹងប្រាក់រៀល (ក្រុម "ក")

II. **សម្រាប់រង្វាន់ជាសាច់ប្រាក់ចំនួន ២៥០ ដុល្លារៈ**
- អតិថិជន របស់សាជីវកម្មធនាគារកាថេយ្យូណៃធីត(កម្ពុជា)ចំកាត់ ទាំងអស់ត្រូវមានប្រតិបត្តិការទទួលប្រាក់ពីធនាគារដទៃ តាមរយ: KHQR ចាប់ពី៣០ដងឡើងទៅ
- អតិថិជនត្រូវមានសមតុល្យជាមធ្យមប្រចាំខែពី ១, ០០០.០១ រហូតដល់ ១០,០០០.០០ ដុល្លារ ឬសមមូលនឹងប្រាក់រៀល (ក្រុម "ខ")

ការចាប់រង្វាន់សម្រាប់ក្រុម "ក" និង "ខ" នឹងធ្វើឡើង រួចប្រកាសក្នុងរយៈពេល ១៥ ថ្ងៃនៃថ្ងៃធ្វើការនៅខែបន្ទាប់ រហូតដល់ប្រូម៉ូសិនអស់សុពលភាព។

III. **សម្រាប់ការចាប់រង្វាន់ជាសាច់ប្រាក់ចំនួន ៥០០ ដុល្លារៈ**
- អតិថិជន របស់សាជីវកម្មធនាគារកាថេយ្យូណៃធីត(កម្ពុជា)ចំកាត់ ដែលបំពេញលក្ខខណ្ឌរបស់ ក្រុម "ក" ឬក្រុម "ខ" ពេញលេញ ច្រើនជាង ឬស្មើ ០៣ខែ ក្នុងកំឡុងពេលកម្មវិធីប្រូម៉ូសិន នឹងមានសិទ្ធចូលរួមក្នុងការចាប់រង្វាន់ធំចុងក្រោយដែលនឹងធ្វើឡើងក្រោយកម្មវិធីប្រូម៉ូសិនបានបញ្ចប់
- អតិថិជនដែលមិនទាន់ឈ្នះរង្វាន់ជាសាច់ប្រាក់ ១០០ ដុល្លារ ឬ  ២៥០ ដុល្លារ ពេញមួយអំឡុងពេលផ្តល់រង្វាន់ នឹងមានសិទ្ធិទទួលបានប្រូម៉ូសិនចាប់ឆ្នោតចុងក្រោយនេះ

ការចាប់រង្វាន់ធំចុងក្រោយតែមួយលើកនេះនឹងធ្វើឡើង រួចប្រកាសក្នុងរយៈពេល ១៥ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីប្រូម៉ូសិននេះត្រូវបានបញ្ចប់។

**៥. ខចែង និងលក្ខខណ្ឌ**

- អត្រាការប្រាក់បន្ថែម នឹងត្រូវបានបញ្ចូលទៅគណនី CUBC របស់អតិថិជនដោយផ្ទាល់ក្នុងរយៈពេល ១៥ ថ្ងៃនៃថ្ងៃធ្វើការនៃខែបន្ទាប់ ពេញមួយរយៈពេលនៃការផ្សព្វផ្សាយ។
- រាល់ការទទួលទឹកប្រាក់ទូទាត់ KHQR ពីធនាគារផ្សេងទៀតត្រូវមានអប្បបរមា២ដុល្លារ ឬសមមូលនឹងប្រាក់រៀល។
- អតិថិជនម្នាក់ៗមានសិទ្ធិទទួលបានរង្វាន់ជាសាច់ប្រាក់តែម្តងប៉ុណ្ណោះ ក្នុងអំឡុងពេលប្រូម៉ូសិន។
- អតិថិជនមានសិទ្ធិទទួលបានការប្រាក់បន្ថែម P.A. ១.៥% ជារៀងរាល់ខែ ប្រសិនបើសមតុល្យជាមធ្យមរបស់អតិថិជនមានចាប់ពី ៥០០ដុល្លារ រហូតដល់ ១០, ០០០.០០ដុល្លារ ឬសមមូលនឹងប្រាក់រៀល ថែមទាំងទទួលប្រតិបត្តិការពីធនាគារដទៃលើសពី ១០ដង ។ អត្រាការប្រាក់ខ្ពស់បំផុតគិតជាទឹកប្រាក់រហូតដល់ ១៥ ដុល្លារក្នុងមួយខែ។
- ចំនួនប្រតិបត្តិការមិនអាចរួមបញ្ចូលជាមួយគណនីរួមផ្សេងទៀតរបស់អតិថិជនបានទេ។
- សម្រាប់ប្រតិបត្តិការក្រោមការធ្វើឡើងដោយអ្នកផ្ញើដូចគ្នាអាចរាប់បានតែមួយដងក្នុងមួយថ្ងៃ ។ ធនាគារ CUBC នឹងពិនិត្យមើលប្រតិបត្តិការទាំងអស់ក្នុងករណីមានភាពមិនប្រក្រតីណាមួយកើតឡើង។
- បុគ្គលិកធនាគារ CUBC មិនមានសិទ្ធិក្នុងការចូលរួមកម្មវិធីប្រូម៉ូសិននេះទេ។
- សាជីវកម្មធនាគារកាថេយ្យូណៃធីត (កម្ពុជា) ចំកាត់ សូមរក្សាសិទ្ធិក្នុងការដកហូតសិទ្ធិចូលរួម របស់អតិថិជនវិញ ប្រសិនបើរកឃើញថាមានការក្លែងបន្លំ។
- ក្រុមការងារ CUBC នឹងទាក់ទងអ្នកឈ្នះតាមរយៈទូរសព្ទ ដើម្បីជូនដំណឹងដល់អតិថិជនដែលឈ្នះរង្វាន់។
- សម្រាប់អ្នកឈ្នះរង្វាន់ ដែលក្រុមការងារ សាជីវកម្មធនាគារកាថេយ្យូណៃធីត(កម្ពុជា)ចំកាត់ មិនអាចទាក់ទងបាន បី (០៣)ដងជាប់ៗគ្នា នឹងត្រូវចាត់ទុកជាមោឃៈ។
- រង្វាន់នឹងត្រូវបានប្រគល់ជូននៅទីស្នាក់ការកណ្តាលរបស់ សាជីវកម្មធនាគារកាថេយ្យូណៃធីត(កម្ពុជា)ចំកាត់ ជាមួយនឹងភស្តុតាងត្រឹមត្រូវ សម្រាប់ទទួលយករង្វាន់។ អតិថិជនឈ្នះ

រង្វាន់ត្រូវភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ (NID) ដើម្បីបញ្ជាក់អត្តសញ្ញាណរបស់គាត់ដើម្បីទទួលបានរង្វាន់។ ប្រសិនបើអតិថិជន មិនបានផ្តល់ឯកសារត្រឹមត្រូវដើម្បីបញ្ជាក់ពីភាពជាម្ចាស់គណនីរបស់គាត់ទេ នោះរង្វាន់នឹងត្រូវចាត់ទុកជាមោឃៈ។ ដើម្បីជៀសវាងការសង្ស័យ ព័ត៌មានលម្អិតអំពីឯកសារអត្តសញ្ញាណដែលផ្តល់ដោយអតិថិជនត្រូវតែពិត និងត្រូវគ្នា ១០០% ជាមួយនឹងព័ត៌មានលម្អិតដែលបានបញ្ចូលទៅក្នុងគណនីឌីជីថល CUBC ។ បន្ទាប់មក ធនាគារនឹងដាក់ប្រាក់រង្វាន់ទៅក្នុងគណនី CUBC របស់អតិថិជនក្នុងរយៈពេល ០៧ ថ្ងៃធ្វើការ។

- រាល់ការចំណាយដែលកើតឡើងដោយការចាប់រង្វាន់ ផ្អែកលើការឈ្នះរង្វាន់ រួមបញ្ចូលពន្ធ ការដឹកជញ្ជូន និងការគិតថ្លៃផ្សេងទៀតជាទំនួលខុសត្រូវរបស់អតិថិជនដែលឈ្នះ។
- សាជីវកម្មធនាគារកាថេយ្យូណៃធីត (កម្ពុជា) ចំកាត់ សូមរក្សាសិទ្ធិក្នុងការបង្ហោះឈ្មោះ និងរូបថតរបស់អ្នកឈ្នះនៅក្នុងបណ្តាញសង្គម និងផ្សព្វផ្សាយជាសាធារណៈ។
- ការខកខានក្នុងការអនុវត្តតាមប្រការដែលបានចែងខាងលើនឹងត្រូវចាត់ទុកជាមោឃៈ ហើយគ្មានការផ្តល់ជាប្រាក់ឬវត្ថុជំនួសនឹងផ្តល់ជូនទាំងស្រុងឬដោយផ្នែកឡើយ។
- ក្នុងកម្រិតដែលអនុញ្ញាតដោយច្បាប់ និងបទប្បញ្ញត្តិ និងដើម្បីការពារផលប្រយោជន៍អាជីវកម្មស្របច្បាប់របស់សាជីវកម្មធនាគារកាថេយ្យូណៃធីត (កម្ពុជា) ចំកាត់ យើងខ្ញុំសូមរក្សាសិទ្ធិគ្រប់យ៉ាងក្នុងការសម្រេចចិត្តបញ្ចប់កម្មវិធីប្រូម៉ូសិន ព្រមទាំងការផ្លាស់ប្តូរ បន្ថែម ឬលុបចោលទៅលើលក្ខខណ្ឌនានាដោយមិនចាំបាច់មានការជូនដំណឹងជាមុន ឬការយល់ព្រមពីអតិថិជន។
- សាជីវកម្មធនាគារកាថេយ្យូណៃធីត (កម្ពុជា) ចំកាត់រក្សាសិទ្ធិក្នុងការបកស្រាយបញ្ហាណាមួយដែលមិនបានចែងក្នុងលក្ខខណ្ឌនេះ។
- សាជីវកម្មធនាគារកាថេយ្យូណៃធីត (កម្ពុជា) ចំកាត់នឹងខិតខំប្រឹងប្រែងដោះស្រាយនូវវិវាទដែលអាចកើតមានឡើងទាក់ទងនឹងប្រូម៉ូសិននេះ ឱ្យអស់ពីលទ្ធភាពស្របតាមគោលការណ៍របស់ធនាគារ។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រផ្លូវការរបស់សាជីវកម្មធនាគារកាថេយ្យូណៃធីត (កម្ពុជា) ចំកាត់ www.cathaybk.com.kh/ ឬលោកអ្នកអាចទាក់ទងមកកាន់ក្រុមការងារផ្នែកសេវាអតិថិជនរបស់យើងខ្ញុំតាមរយៈលេខទូរសព្ទ៖ ០២៣ ៨៨ ៥៥ ០០/០៦៩ ៨៨ ៥៥ ០០។